អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# កាំង ហ្គេកអ៊ាវ ហៅ ឌុច



**គោត្តនាម:** កាំង | **នាម:** ហ្គេកអ៊ាវ

**សំណុំរឿងលេខ** ៖ ០០១/១៨-០៧-២០០៧/អវតក-អជតក

**សវនាការសាធារណៈបន្ទាប់៖** ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១១
សវនាការលើបណ្តឹងសាទុក្ខ

**កាលបរិច្ឆេទនិងទីកន្លែងកំណើត** ៖ ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ១៩៤២ នៅភូមិពៅវើយ ឃុំពាមបាង ស្រុកស្ទោង ខេត្តកំពង់ធំ

**កាលបរិច្ឆេទបញ្ជូនខ្លួនមកពីមន្ទីរឃុំឃាំងរបស់តុលាការយោធា** ៖ ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧

**មេធាវីការពារក្តី៖** លោក ការ សាវុត្ថ (មេធាវីជាតិ) និងលោក កង រិទ្ធារី (មេធាវីជាតិ)

**ស្ថានភាពបច្ចុប្បន្ន**

បន្ទាប់ពីបានធ្វើសវនាការបឋមនៅថ្ងៃទី១៧ និង១៨ ខែកុម្ភៈ ឆ្នាំ២០០៩ ការជំនុំជម្រះលើអង្គសេចក្តីត្រូវបានចាប់ផ្តើមធ្វើឡើងនៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៩។ ការជំនុំជម្រះ ឌុច បានបញ្ចប់នៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៩។ ក្នុងរយៈពេលជំនុំជម្រះចំនួន ៧៧ថ្ងៃ មានសាក្សីជាអ្នកជំនាញចំនួន៩នាក់ សាក្សីផ្តល់សក្ខីកម្មទាក់ទង នឹងអង្គហេតុចំនួន១៧នាក់ សាក្សីផ្តល់សក្ខីកម្មទាក់ទងនឹងអត្តចរិតចំនួន៧នាក់ និងដើមបណ្តឹងរដ្ឋប្បវេណីចំនួន២២នាក់ បានឡើងបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ មានមនុស្សចំនួនជាង ៣១.០០០នាក់ បានតាមដានដំណើរការនីតិវិធីនេះដោយផ្ទាល់នៅសាលសវនាការ។

នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ អង្គជំនុំជម្រះសាលាដំបូងបានដាក់ទោស កាំង ហ្គេកអ៊ាវ និងផ្តន្ទាទោសឲ្យជាប់ពន្ធនាគាររយៈពេល៣៥ឆ្នាំ។ ទោសនេះត្រូវបានកាត់បន្ថយរយៈពេល៥ឆ្នាំ ជាសំណងចំពោះការឃុំខ្លួនគាត់ខុសនីតិវិធីច្បាប់ដោយតុលាការ

# ព័ត៌មានទាក់ទងនឹងសំណុំរឿង

| | |
|---|---|
| | យោធាកម្ពុជា ពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ ដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧។ ជនត្រូវចោទក៏ទទួលបាននូវការទទួលស្គាល់នូវរយៈពេលឃុំខ្លួននៅក្រោមសមត្ថកិច្ចរបស់តុលាការយោធាកម្ពុជាចាប់ពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ រហូតដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧ និងរយៈពេលឃុំខ្លួនបណ្តោះអាសន្ននៅក្រោមសមត្ថកិច្ចរបស់ អ.វ.ត.ក ចាប់ពីថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧ រហូតដល់ថ្ងៃដែលសាលក្រមនេះចូលជាធរមាន។<br><br>ជនត្រូវចោទ និងសហព្រះរាជអាជ្ញា បានប្តឹងសាទុក្ខទៅអង្គជំនុំជម្រះតុលាការកំពូលជំទាស់ទៅនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង។ ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនក៏បានប្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងសំណងផ្លូវចិត្តនិងការបដិសេធភាពអាចទទួលយកបាននៃពាក្យសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណី។<br><br>អង្គជំនុំជម្រះតុលាការកំពូលនឹងបើកសវនាការសាធារណៈទៅលើបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង០០១ នៅសប្តាហ៍ចុងក្រោយនៃខែមីនា ឆ្នាំ២០១១។ |
| **តួនាទីក្នុងរបបកម្ពុជាប្រជាធិបតេយ្យ** | ជាអនុលេខា បន្ទាប់មកជាលេខាគណៈកម្មាធិការមន្ទីរ ស-២១ (មន្ទីរសន្តិបាលដែលត្រូវបានស្គាល់ជាទូទៅថា គុកទួលស្លែង) |
| **បទចោទប្រកាន់សំខាន់ៗ** | នៅក្នុងសាលក្រមថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ អង្គជំនុំជម្រះសាលាដំបូងរកឃើញថា ឌុច មានទោសទៅតាមមាត្រាទី៥ ទី៦ និងទី២៩(ថ្មី) នៃច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ចំពោះបទល្មើសទាំងប៉ុន្មានខាងក្រោម ដែលត្រូវបានប្រព្រឹត្តនៅទីក្រុងភ្នំពេញក្នុងទឹកដីនៃប្រទេសកម្ពុជា ចន្លោះពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩៖<br><br>**ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ៖**<br>• ការរើសអើងដោយសារហេតុផលនយោបាយ<br>• ការសម្លាប់រង្គាល (រួមបញ្ចូលទាំងការធ្វើមនុស្សឃាត)<br>• ការធ្វើឲ្យទៅជាទាសករ |

| | | |
|---|---|---|
| | • ការដាក់ក្នុងមន្ទីរឃុំឃាំង<br>• ការធ្វើទារុណកម្ម (រួមទាំងការរំលោភលើផ្លូវភេទមួយករណី)<br>• និងអំពីអមនុស្សធម៌ផ្សេងៗទៀត។<br>**ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩៖**<br>• ការធ្វើមនុស្សឃាតដោយចេតនា<br>• ការធ្វើទារុណកម្ម និងការធ្វើបាបដោយអមនុស្សធម៌<br>• ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព<br>• ការដកហូតដោយចេតនាពីឈ្លើយសឹកឬជនស៊ីវិល នូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌និងទៀងទាត់<br>• និង ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់។ | |
| **ព័ត៌មានផ្ទាល់ខ្លួន** | នៅក្នុងឆ្នាំ១៩៦៥ ឌុច បានក្លាយទៅជាគ្រូបង្រៀនផ្នែកគណិតវិទ្យា ហើយមួយរយៈក្រោយមក គាត់ត្រូវបានចោទថាបានចូលរួមជាមួយបក្សកុម្មុយនីស្តកម្ពុជា។ គាត់ត្រូវប៉ូលីសរបស់សម្តេច សីហនុ ចាប់ខ្លួនក្នុងឆ្នាំ១៩៦៨ ប៉ុន្តែត្រូវបានដោះលែងឲ្យមានសេរីភាពវិញនៅពេលរដ្ឋប្រហារទម្លាក់សម្តេចសីហនុនៅឆ្នាំ១៩៧០។ ពីខែកក្កដា ឆ្នាំ១៩៧១ ដល់ខែមករា ឆ្នាំ១៩៧៥ ឌុច មានតួនាទីជាប្រធានការិយាល័យទី១៣ ឬ ម-១៣ (គឺជាមន្ទីរសន្តិសុខមួយទៀតរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលមានទីតាំងនៅភាគខាងជើងទីក្រុងភ្នំពេញ)។ ឌុច បន្តចូលរួមជាមួយខ្មែរក្រហមរហូតដល់ដើមទសវត្សរ៍ឆ្នាំ១៩៩០ ទើបគាត់ត្រឡប់មកធ្វើជាគ្រូបង្រៀនវិញ។ បន្ទាប់ពីមរណភាពរបស់ប្រពន្ធគាត់ដោយសារអំពើប្លន់នៅឆ្នាំ១៩៩៥ ឌុច បានប្តូរមកកាន់សាសនាគ្រិស្ត និងបានផ្លាស់ទៅរស់នៅស្រុកសំឡូត រហូតដល់ពេលដែលគាត់ត្រូវបានប្រទះឃើញដោយអ្នកសារព័ត៌មានមួយរូបក្នុងឆ្នាំ១៩៩៩។ បន្ទាប់ មក ឌុច ត្រូវបានចាប់ខ្លួនដោយកងទ័ពកម្ពុជា។ | |
| **ប្រវត្តិនៃសំណុំរឿង** | ៣១ កក្កដា ២០០៧ | កាំង ហ្កេកអ៊ាវ ត្រូវបានបញ្ជូនមកពីមន្ទីរឃុំឃាំងរបស់តុលាការយោធា និងត្រូវបានឃុំខ្លួននៅ អ.វ.ត.ក សម្រាប់ |

| | | |
|---|---|---|
| | | រយៈពេល១ឆ្នាំ តាមដីកាឃុំខ្លួនបណ្តោះអាសន្នដែលចេញដោយសហចៅក្រមស៊ើបអង្កេត។ |
| | ៥ កញ្ញា ២០០៧ | កាំង ហ្គេកអ៊ាវ ដាក់ពាក្យបណ្តឹងសាទុក្ខទៅអង្គបុរេជំនុំជម្រះ ជំទាស់នឹងដីកាឃុំខ្លួនគាត់ជាបណ្តោះអាសន្ន។ |
| | ៣ ធ្នូ ២០០៧ | អង្គបុរេជំនុំជម្រះបដិសេធបណ្តឹងសាទុក្ខជំទាស់នឹងដីកាឃុំខ្លួនបណ្តោះអាសន្ន។ |
| | ២៨ កក្កដា ២០០៨ | សហចៅក្រមស៊ើបអង្កេតចេញដីកាពន្យារពេលឃុំខ្លួន កាំង ហ្គេកអ៊ាវ ហៅ ឌុច ជាបណ្តោះអាសន្ន សម្រាប់រយៈពេលមួយឆ្នាំទៀត។ |
| | ៨ សីហា ២០០៨ | សហចៅក្រមស៊ើបអង្កេតចេញដីកាដំណោះស្រាយ ដោយចោទប្រកាន់ កាំង ហ្គេកអ៊ាវ ហៅ ឌុច និងបញ្ជូនសំណុំរឿងទៅជំនុំជម្រះ។ |
| | ៥ កញ្ញា ២០០៨ | សហព្រះរាជអាជ្ញាដាក់ពាក្យបណ្តឹងសាទុក្ខទៅអង្គបុរេជំនុំជម្រះ ប្រឆាំងនឹងដីកាដំណោះស្រាយ ដោយសំណូមពរឲ្យអង្គបុរេជំនុំជម្រះធ្វើវិសោធនកម្មលើបទចោទប្រកាន់ |
| | ៥ ធ្នូ ២០០៨ | អង្គបុរេជំនុំជម្រះសម្រេចយល់ព្រមផ្នែកខ្លះទៅលើសំណើរបស់សហព្រះរាជអាជ្ញា ដែលសុំឲ្យធ្វើសមាហរណកម្មលើបទចោទប្រកាន់។ |
| | ១៧-១៨ កុម្ភៈ ២០០៩ | កាំង ហ្គេកអ៊ាវ បង្ហាញខ្លួននៅចំពោះមុខសវនាការបឋមនៃអង្គជំនុំជម្រះសាលាដំបូង |
| | ៣០ មីនា ២០០៩ | អង្គជំនុំជម្រះសាលាដំបូងចាប់ផ្តើមដំណើរការសវនាការលើអង្គហេតុ |
| | ១៥ មិថុនា ២០០៩ | អង្គជំនុំជម្រះសាលាដំបូងបដិសេធបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី ប្រឆាំងនឹងការបន្តឃុំខ្លួន កាំង ហ្គេកអ៊ាវ |

| | | |
|---|---|---|
| | ២៣-២៧ វិច្ឆិកា ២០០៩ | ភាគីនីមួយៗធ្វើសេចក្តីសន្និដ្ឋានបញ្ចប់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង |
| | ២៦ កក្កដា ២០១០ | អង្គជំនុំជម្រះសាលាដំបូងចេញសាលក្រមកាត់ទោស កាំង ហ្កេកអ៊ាវ ចំពោះបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និង ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ និងផ្តន្ទាទោសឲ្យជាប់ពន្ធនាគាររយៈពេល៣៥ឆ្នាំ។ សាលក្រមត្រូវបានកាត់បន្ថយរយៈពេល៥ឆ្នាំ ជាការទូទាត់ចំពោះការឃុំឃាំងខ្លួនគាត់ខុសនីតិវិធីច្បាប់ដោយតុលាការយោធាកម្ពុជា។ |
| | ១៦ សីហា ២០១០ | សហព្រះរាជអាជ្ញាបានចេញសេចក្តីជូនដំណឹងជាផ្លូវការទៅអង្គជំនុំជម្រះសាលាដំបូងនិងអង្គជំនុំជម្រះតុលាការកំពូល ថា ការិយាល័យសហព្រះរាជអាជ្ញានឹងដាក់ពាក្យបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមដែលចេញដោយអង្គជំនុំជម្រះសាលាដំបូងនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០។ |
| | ២៤ សីហា ២០១០ | តាមរយៈមេធាវីរបស់ខ្លួន កាំង ហ្កេកអ៊ាវ បានចេញសេចក្តីជូនដំណឹងជាផ្លូវការទៅអង្គជំនុំជម្រះសាលាដំបូងនិងអង្គជំនុំជម្រះតុលាការកំពូល ថា គាត់នឹងដាក់ពាក្យបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមដែលចេញដោយអង្គជំនុំជម្រះសាលាដំបូងនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០។ |
| | ១៣ តុលា ២០១០ | សហព្រះរាជអាជ្ញាបញ្ជូនពាក្យបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមសម្រេចដោយអង្គជំនុំជម្រះសាលាដំបូងនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ទៅអង្គជំនុំជម្រះតុលាការកំពូល។ |
| | ១៨ វិច្ឆិកា ឆ្នាំ២០១០ | តាមរយៈមេធាវីរបស់ខ្លួន កាំង ហ្កេកអ៊ាវ បញ្ជូនពាក្យបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមសម្រេចដោយអង្គជំនុំជម្រះសាលាដំបូងនៅថ្ងៃ ទី២៦ ខែកក្កដា ឆ្នាំ២០១០ ទៅអង្គជំនុំជម្រះតុលាការកំពូល។ |

## ព័ត៌មានទាក់ទងនឹងសំណុំរឿង

| | | |
|---|---|---|
| | ២៨-៣០ មីនា ២០១១ | ឌុចបានបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលនៅក្នុងសវនាការលើបណ្តឹងសាទុក្ខ |
| | ៣ កុម្ភៈ ២០១២ | អង្គជំនុំជម្រះតុលាការកំពូលប្រកាសសាលដីការស្តាពរលើបណ្តឹងសាទុក្ខ |

*ដីកានិងសេចក្តីសម្រេចទាំងនេះនិងផ្សេងៗទៀត: http://www.eccc.gov.kh/english/court_doc.list.aspx

## អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ព័ត៌មានទាក់ទងនឹងសំណុំរឿងនេះរៀបចំដោយផ្នែកកិច្ចការសាធារណៈនៃ អ.វ.ត.ក ដើម្បីជាជំនួយដល់សាធារណជន ឲ្យមានការយល់ដឹងអំពីសំណុំរឿងនៅចំពោះមុខ អ.វ.ត.ក។ ឯកសារនេះពុំមែនជាឯកសារផ្លូវការផ្នែកច្បាប់ណាមួយនោះទេ បើទោះបីជាមានការខិតខំប្រឹងប្រែងអស់ពីលទ្ធភាពដើម្បីធានាដល់តម្លាភាពព័ត៌មានក៏ដោយ។

**ទាក់ទងយើង:** ផ្លូវជាតិលេខ 4 សង្កាត់ចោមចៅ ខណ្ឌដង្កោ ប្រអប់សំបុត្រលេខ 71 ភ្នំពេញ កម្ពុជា
ទូរស័ព្ទ: (855) 23 219814
ទូរសារ: (855) 23 219841
អ៊ីម៉ែល: info@eccc.gov.kh

**http://www.eccc.gov.kh**